ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍បាត់ដំបង

សំណុំរឿងសភាព្រហ្មទណ្ឌលេខ ២៣៨
ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

**សាលដីកា**

លេខ ៤៤៨ "ជ"
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍បាត់ដំបង**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍បាត់ដំបង នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ដោយមានសមាសភាពដូចខាងក្រោម ៖

17-10-22
ស៧ 12៤

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាឧទ្ធរណ៍

ដើម្បីជំនុំជម្រះបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងសភាព្រហ្មទណ្ឌលេខ ២៣៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ មានដូចខាងក្រោម ៖

**-ជនជាប់ចោទមាន៖**

១.ឈ្មោះ [redacted] សារឿន ភេទស្រី អាយុ ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ កើតនៅភូមិត្រាំ សសេរ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ទីលំនៅបច្ចុប្បន្នក្រុមទី១២ ភូមិថ្នល់បត់ ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ប្តីឈ្មោះ [redacted] មានកូនចំនួន ០៥នាក់ ឪពុកឈ្មោះ [redacted] (ស្លាប់) ម្តាយឈ្មោះ [redacted] ស្លាប់) កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុន "គ្មាន" ។ (ក្រៅឃុំ) (អ្នកប្តឹងឧទ្ធរណ៍)



Scanned with CamScanner

២.ឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ មុខរបរកម្មករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិថ្មល់បត់ ឃុំអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រស់) ម្តាយឈ្មោះ [redacted] (រស់) កម្រិតវប្បធម៌ថ្នាក់ទី៥ ទោសពីមុន "គ្មាន"។(ក្រៅឃុំ) (មិនប្តឹងឧទ្ធរណ៍)

ជាប់ចោទពីបទ ហិង្សាស្រាល ប្រព្រឹត្តនៅចំណុចក្រុមទី០៩ ភូមិថ្មល់បត់ ឃុំអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] សុខា ភេទស្រី អាយុ ៥៣ឆ្នាំ កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិថ្មល់បត់ ឃុំអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១៨ និង៣០ នាទី នៅចំណុចក្រុមទី០៩ ភូមិថ្មល់បត់ ឃុំអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង មានករណីហិង្សាស្រាលមួយបានកើតឡើងដែលបង្កដោយឈ្មោះ [redacted] សារឿន ភេទស្រី និងឈ្មោះ [redacted] ស្រីលីន ភេទស្រី បានចាប់ម្តួលជនរងគ្រោះឈ្មោះ [redacted] សុខា ភេទស្រី ទៅលើដី ហើយមានការចាប់ប្រតាយប្រតប់គ្នាបន្តិចបន្តួច បណ្តាលឱ្យជនរងគ្រោះមានស្នាមបន្តិច ក្រោយមកមានអ្នកជិតខាងបានមកជួយធ្វើការឃាត់អ្នកទាំង នោះចេញពីគ្នា។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៥១ "ច" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេច៖

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទស្រី អាយុ ៤៨ឆ្នាំ និងឈ្មោះ [redacted] ស្រី លីន ភេទស្រី អាយុ ១៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) ពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ១០០.០០០(មួយសែន)រៀល ពីបទ: "ហិង្សាស្រាល" ប្រព្រឹត្តនៅចំណុចក្រុមទី០៩ ភូមិថ្មល់បត់ ឃុំអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] សារឿន ភេទស្រី អាយុ៤៨ឆ្នាំ និងឈ្មោះ [redacted] ស្រីលីន ភេទស្រី អាយុ១៨ឆ្នាំ (មានអត្តសញ្ញាណដូចខាងលើ) រួមគ្នាសងសំណងជម្ងឺចិត្តទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា ចំនួន ២.០០០.០០០(ពីរលាន)រៀល។ ការទាមទារលើសពីនេះ ច្រាន ចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារឿន និងឈ្មោះ [redacted] ស្រីលីន និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សារឿន បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥១ "ច" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្តីសម្រេចបញ្ចប់ទាំងមូល។



Scanned with CamScanner

-បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះលេខ ២៥០ ព្រទ.ឧបប/២២ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍បាត់ដំបង ។

-បានឃើញ របាយការណ៍រឿងសភាព្រហ្មទណ្ឌ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍បាត់ដំបង ។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍សង្ខេបរឿង

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខា បានឆ្លើយថា៖ រឿងហេតុដំបូង ខ្លួនបានចូលទៅប្រាប់គាត់អំពីរឿងទឹកហូរ ដើម្បីឱ្យគាត់ទៅកាប់រណ្តៅដាក់ទុយោ ក៏ប៉ុន្តែគាត់មិនបានយល់ស្របទេ ហើយក៏បានឈ្លោះទាស់សំដីគ្នា និងនិយាយថាចង់វាយខ្លួន ពេលនោះក៏មានការឈ្លោះប្រកែកវាយគ្នាតែម្តង ។ ឈ្មោះ [redacted] សារឿន បានចាប់បោចសក់ខ្លួន ថែមទាំងបានខ្វាចខ្លួន និងចាប់កខ្លួនផងដែរ ហើយកូនគាត់ឈ្មោះ [redacted] ស្រីលីន បានចូលមកគ្រៀកខ្លួនជាប់ ។ ឈ្មោះ [redacted] សារឿន បានវាយខ្លួននឹងដៃទទេ ។ នៅពេលឈ្លោះគ្នានោះគឺមានរយៈពេលប្រហែលជា ២០នាទី ចំណែកឯឃ្លីបវីដេអូជាភស្តុតាងនោះ គឺប្តីខ្លួនជាអ្នកថត ។

-ឈ្មោះ [redacted] ស្រីលីន បានឆ្លើយថា៖ នៅពេលដែលម្តាយខ្លួន និងឈ្មោះ [redacted] សុខា កំពុងតែប្រតាយប្រតប់គ្នានោះ គឺខ្លួនបានចូលទៅជួយឃាត់ដែរតែឃាត់មិនឈ្នះ ។ ដោយនៅពេលនោះខ្លួនបានចូលទៅជួយឃាត់ខាងឈ្មោះ [redacted] សុខា មូលហេតុបានជា ខ្លួនមិនចាប់ឃាត់ខាងម្តាយព្រោះនៅពេលនោះឈ្មោះ [redacted] សុខា កំពុងតែបោចសក់គ្នាជាមួយម្តាយខ្លួន ។ ខ្លួនចូលទៅជួយឃាត់នោះក្នុងគោលបំណងបំបែកគ្នា ហើយក៏មិនបានប៉ះពាល់ ឬវាយឈ្មោះ [redacted] សុខា នោះដែរ ។

-តំណាងមហាអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យពិចារណា និងសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿងព្រហ្មទណ្ឌ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យ និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សាលាឧទ្ធរណ៍បាត់ដំបង</u>**

**<u>យល់ឃើញថា</u>**



Scanned with CamScanner

១-ពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សារឿន បានប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៥១ “ច” ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០២២ របស់សាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចសេចក្ដីសម្រេចទាំងមូល ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍បាត់ដំបងអាចទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា ៣៨២ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-រឿងក្ដីនេះជនជាប់ចោទមានចំនួន ០២នាក់ ប៉ុន្ដែជនជាប់ចោទឈ្មោះ [redacted]សារឿន បានប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចប៉ុណ្ណោះ ។ ដូច្នេះ ក្រុមប្រឹក្សាសាលាឧទ្ធរណ៍លើកយកតែករណីប្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទមកពិនិត្យ និងពិចារណា ប៉ុណ្ណោះ ។

៣-កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ មានករណីហិង្សាស្រាលមួយបានកើតឡើងដែលកើតឡើងដែលបង្កដោយឈ្មោះ[redacted]ារឿន ភេទស្រី និងឈ្មោះ [redacted] ស្រីលីន ភេទស្រី បានចាប់ផ្ដួលជនរងគ្រោះឈ្មោះ[redacted]សុខា ភេទស្រី ទៅលើដី ហើយមានការចាប់ប្រតាយប្រតប់គ្នាបន្ដិចបន្ដួចបណ្ដាលឱ្យជនរងគ្រោះមានស្នាមបន្ដិច ។ តាមអំពើរបស់ជនជាប់ចោទនេះត្រូវបានសាលាដំបូងខេត្តបាត់ដំបងផ្ដន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ារឿន រូបនេះ ពីបទ ហិង្សាស្រាល ដាក់ពន្ធនាគារពិន័យជាប្រាក់ចំនួន ១០០ .០០០ (មួយសែន)រៀល ។

៤-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានឆ្លើយថា រឿងហេតុដំបូង ខ្លួនបានចូលទៅប្រាប់គាត់អំពីរឿងទឹកហូរ ដើម្បីឱ្យគាត់ទៅកាប់រណ្ដៅដាក់ទុយោ ក៏ប៉ុន្ដែគាត់មិនបានយល់ស្របទេ ហើយក៏បានឈ្លោះទាស់សំដីគ្នា និងនិយាយថាចង់វាយខ្លួន ពេលនោះក៏មានការឈ្លោះប្រកែកវាយគ្នាតែម្ដង ។ ឈ្មោះ[redacted]សារឿន បានចាប់បោចសក់ខ្លួន ថែមទាំងបានខ្វាចខ្លួន និងចាប់កខ្លួនផងដែរ ហើយកូនគាត់ឈ្មោះ[redacted]ស្រីលីន បានចូលមកគៀកខ្លួនជាប់ ។ ឈ្មោះ [redacted]សារឿន បានវាយខ្លួននឹងដៃទទេរ ។ ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបងថា ដោយសារតែរឿងទឹកហូរជ្រាបនៅកន្លែងបន្ទប់ទឹកក្បែរដើមដូង ហើយខ្លួនក៏បានឈ្លោះទាស់សំដីគ្នា និងបានវាយគ្នាទៅវិញទៅមកដោយដៃទទេរជាមួយដើមបណ្ដឹងរដ្ឋប្បវេណីតែម្ដង ។ តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាចម្លើយរបស់ជនជាប់ចោទបានបញ្ជាក់ឱ្យក្រុមប្រឹក្សាជំនុំជម្រះឃើញថា ជនជាប់ចោទឈ្មោះ[redacted]សារឿន ពិតជា បានប្រព្រឹត្តអំពើហិង្សាស្រាលទៅលើដើមបណ្ដឹងរដ្ឋប្បវេណីពិតប្រាកដមែន ។

៥-តំណាងមហាអយ្យការបានសន្និដ្ឋានថាស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់ ។ សេចក្ដីសន្និដ្ឋាននេះមានទឡ្ហីករណ៍ត្រឹមត្រូវ ដែលអាចឲ្យក្រុមប្រឹក្សាលើកយកមកពិចារណា និងសម្រេចបានដូចការយល់ឃើញខាងលើ ។



Scanned with CamScanner

៦-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] សាវឿន ភេទស្រី អាយុ ៤៨ឆ្នាំ ពីបទ ៖ ហិង្សាស្រាល ប្រព្រឹត្តនៅចំណុចក្រុមទី០៩ ភូមិថ្មល់បត់ ឃុំអូររំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨ នៃក្រមព្រហ្មទណ្ឌ ។

៧-សាលក្រមព្រហ្មទណ្ឌលេខ ៤៥១"ច" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ គប្បីរក្សាទុកជាបានការដដែល ។

## ហេតុដូច្នេះ
## ទិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ របស់ជនជាប់ចោទឈ្មោះ [redacted] សាវឿន ទុកជាត្រឹមត្រូវតាមច្បាប់ តែបដិសេធចោលដោយខាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៥១"ច" ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២ កំបាំងមុខជនជាប់ចោទ ដោយចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

រក្សាសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**
ហត្ថលេខា
[redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា
[redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា
[redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា
[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍បាត់ដំបង, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២

**បានឃើញ**
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner